**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ព្រឹទ្ធសភា**
**អគ្គលេខាធិការដ្ឋាន**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែវិច្ឆិកា និងទិសដៅការងារខែធ្នូ ឆ្នាំ២០១៨

**សេចក្តីផ្តើម**:

នៅក្នុងខែវិច្ឆិកានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម និងមមាញឹកលើគ្រប់ការដ្ឋាន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរតាមរយៈលទ្ធផលសំខាន់ៗដូចខាងក្រោមៈ

I.**លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**:

**១.មុខងារនីតិកម្ម**:

| *របនាសម្ព័ន្ធនយោបាយ* | *របនាសម្ព័ន្ធរដ្ឋបាល* |
|---|---|
| - ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន ០២លើក ប្រជុំពេញអង្គព្រឹទ្ធសភាចំនួន ០១លើក ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ដូចខាងក្រោមៈ<br>១-សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩<br>២-សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧<br>៣-សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រីដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិលើៈ កិច្ចព្រមព្រៀងស្តីពី ការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគេច | - បានចាត់ចែងនីតិវិធី ឯកសារពាក់ព័ន្ធ ធ្វើកំណត់-ហេតុសង្ខេប និងពិស្តារនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៤<br>- បានសម្អាត តុបតែងសាល ផ្គត់ផ្គង់ និងផ្តល់សេវាភេសជ្ជៈ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំផ្សេងៗ សរុបចំនួន០២លើក មានអ្នកចូលរួមចំនួន១០៦នាក់<br>- បានថតចម្លងឯកសារចំនួន៨៣១ច្បាប់ អស់ក្រដាសចំនួន១០,៩១៤សន្លឹក<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង និងកម្លាំងអន្តរាគមន៍ពីខាងក្រៅស្ថាប័នចំនួន១៧៥នាក់ ស្មើនឹង០៥លើក<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក |

| | |
|---|---|
| កេីងបន្ទុំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូលរវាង(កម្ពុជា-វៀតណាម និងកម្ពុជា-ឥណ្ឌូនេស៊ី) និងសន្ធិសញ្ញារវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ីស្តីពី បត្យាប័ន។ | សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន០៧លើក<br>- បានទទួលសេចក្តីព្រាងច្បាប់ចំនួន០៥ច្បាប់ពីរាជរដ្ឋាភិបាល ហើយបានចាត់ចែងតាមនីតិវិធី<br>- បានធ្វើកំណត់បង្ហាញលើព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ដីកាអម សេចក្តីសម្រេច និងលិខិតផ្សេងៗចំនួន៧៧ច្បាប់<br>- បានប្រជុំផ្តល់យោបល់លើឯកសារស្តីពី ការអនុវត្តជាក់ស្តែងនៃដំណើរការពិនិត្យ និងអនុម័តច្បាប់នៅសភាកម្ពុជា<br>- បានសិក្សាស្រាវជ្រាវ និងធ្វើឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ចំនួន០៥ច្បាប់<br>- បានស្រាវជ្រាវ បកប្រែ និងសង្ខេបព័ត៌មានសភាអន្តរជាតិបានចំនួន១៦៧ច្បាប់<br>- បានរៀបចំទីកន្លែងប្រជុំចំនួន០២លើក និងចុះត្រួតពិនិត្យប្រព័ន្ធសំឡេង និងកាមេរ៉ាវីដេអូនៅសាលប្រជុំពេញអង្គ និងសាលប្រជុំគណៈ-កម្មាធិការអចិន្ត្រៃយ៍ចំនួន១៣លើក<br>- បានប្រចាំការថតសំឡេង ថតវីដេអូ និងរៀបចំប្រព័ន្ធសំឡេងចំនួន០១លើក<br>- បានថត និងផ្សព្វផ្សាយព័ត៌មាន សេចក្តីជូនដំណឹង សេចក្តីប្រកាសព័ត៌មានចំនួន០៨លើក។ |

**២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា:**

| *របនាសម្ព័ន្ធនយោបាយ* | *របនាសម្ព័ន្ធរដ្ឋបាល* |
|---|---|
| - សមាជិក សមាជិកាព្រឹទ្ធសភាបាន៖<br>+ អញ្ជើញចុះបេសកកម្ម ដើម្បីស្តាប់សេចក្តីរាយការណ៍ពីចំណុចខ្លាំង ចំណុចខ្សោយ | - បានធ្វើលិខិតបេសកកម្ម ជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៦នាក់ ស្មើនឹង០២ច្បាប់ |

| | |
|---|---|
| បញ្ហាប្រឈម និងសំណូមពររបស់ថ្នាក់ដឹកនាំនៃខេត្តតាកែវ ខេត្តកែប និងខេត្តកំពត ដើម្បីត្រៀមរៀបចំវេទិកាសាធារណៈ និងរិះរកដំណោះស្រាយជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ<br>+ អញ្ជើញចុះបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់ពីវិធានទាំងឡាយនៃការដោះស្រាយវិវាទក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធតុលាការ ព្រមទាំងការអនុវត្តច្បាប់នៅខេត្តព្រះវិហារ។ | - ថត និងផ្សព្វផ្សាយព័ត៌មានសកម្មភាពរបស់សមាជិក សមាជិកាព្រឹទ្ធសភា ចុះបំពេញបេសកកម្មតាមបណ្ដាខេត្ត ក្រុង នានា និងកិច្ចប្រជុំផ្ទៃក្នុងចំនួន០៦លើក ។ |

**៣.មុខងារតំណាង:**

| *វេចនាសម្ព័ន្ធនយោបាយ* | *វេចនាសម្ព័ន្ធរដ្ឋបាល* |
|---|---|
| - សកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា៖<br>+ អញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីប្រទានភ្លើងជ័យ និងពន្លត់ភ្លើងជ័យនៃពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៦៥នៃទិវាបុណ្យឯករាជ្យជាតិ៩វិច្ឆិកា និងពិធីមិទ្ទិញមហាជន ព្រមទាំងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណា ព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅវិមានឯករាជ្យ និងនៅមុខព្រះបរមរាជវាំង<br>+ អញ្ជើញជាគណៈអធិបតីក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប និងសំពះព្រះខែ អកអំបុក ឆ្នាំ២០១៨ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណា ព្រះបាទសម្ដេចព្រះបរមនាថ | - រៀបចំបែបបទ ផ្ដល់សេវា អមដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ជាគណៈអធិបតីក្នុងពិធីផ្លូវការនានា និងកិច្ចប្រជុំផ្សេងៗសរុបចំនួន៣៤០លើក<br>- បានផ្ដល់សេវារដ្ឋបាល ពិធីការ និងទំនាក់ទំនងក្នុងការចុះបេសកកម្មអមដំណើរក្រុមសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សារាជធានីភ្នំពេញ ចុះស្រាវជ្រាវប្រមូលព័ត៌មាន ចុះសិក្សាឈ្វេងយល់ពីការប្រឈម និងសំណូមពររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ចុះចែកអំណោយឧបត្ថម្ភដល់គ្រួសាររងគ្រោះដោយភ្លើងឆេះផ្ទះ និងពិធីសម្ពោធសមិទ្ធផលនានា ព្រមទាំងកម្មវិធីផ្សេងៗនៅខេត្តកំពង់ចាម បន្ទាយមានជ័យ កែប កំពត និងរាជធានីភ្នំពេញ<br>- បានរៀបចំទីកន្លែងសម្រាប់កិច្ចប្រជុំ សិក្ខាសាលា និងពិធីផ្សេងៗចំនួន១០លើក |

| | |
|---|---|
| នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅព្រះពន្លាកណ្តាល មុខព្រះបរមរាជវាំង<br>+ អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខអាជ្ញាធរសង្កាត់ លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ ព្រមទាំងដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តមកពីសាធារណរដ្ឋបារាំងទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ និងខេត្តតាកែវ<br>+ អញ្ជើញប្រារព្ធពិធីបុណ្យសព ពិធីបូជាសព និងពិធីបុណ្យគម្រប់ខួប៧ថ្ងៃ របស់ឧបាសក **សាយ គឹមស៊ាន** ដែលត្រូវជាបងប្រុសបង្កើតរបស់សម្តេចប្រធានព្រឹទ្ធសភា ព្រមទាំងចូលរួមពិធីបុណ្យគម្រប់ខួប ១០០ថ្ងៃ របស់ ឯកឧត្តម **ស ថេង** និងអញ្ជើញជាអធិបតីប្រទានភ្លើងបូជាសព របស់ឧបាសក **ទូន កែម** ជំនួយការផ្ទាល់ របស់សម្តេចប្រធានព្រឹទ្ធសភា និងគោរពវិញ្ញាណក្ខន្ធ និងរំលែកទុក្ខដល់ក្រុមគ្រួសារសពលោកព្រឹទ្ធាចារ្យកិត្យវោហារប្រាជ្ញ ឈួន វីរសិល្បករចាប៉ីដងវែង នៅរាជធានីភ្នំពេញ<br>+ អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ថ្វាយកម្រងផ្កា និងគោរពវិញ្ញាណក្ខន្ធ **ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ** អតីតព្រះមហាវីរក្សត្រ (ព្រះបរមរតនកោដ្ឋ) និងបុព្វការីជន ដែលបានពលីជីវិតក្នុងការទាមទារឯករាជ្យជាតិ បូរណភាពទឹកដីពីប្រទេសអាណានិគម<br>+អញ្ជើញចូលរួមសិក្ខាសាលាស្តីពី ការឈ្វេង | - បានផ្ញើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៣១នាក់ ស្មើនឹង៤០ច្បាប់ និងផ្ញើលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកាព្រឹទ្ធសភាចំនួន០៦ច្បាប់<br>- បានថតចម្លងឯកសារចំនួន២០៨ច្បាប់ អស់ក្រដាសចំនួន២,៧២១សន្លឹក<br>- បានផ្តល់សេវារថយន្តសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន៥២នាក់ ស្មើនឹង១៩៥លើក<br>- បានទទួលលិខិតចូលចំនួន៨១៧ច្បាប់ និងបញ្ជូនលិខិតចេញចំនួន១២០ច្បាប់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន១២៣លើក<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន៤៩នាក់ ស្មើនឹង០៤លើក<br>- បានចូលរួមគោរពវិញ្ញាណក្ខន្ធសពចំនួន០៤លើក<br>- បានចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព មានជំងឺ គ្រោះថ្នាក់ចរាចរណ៍ និងនិវត្តជននៃអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៥នាក់<br>- បានផ្តល់អត្ថបទព័ត៌មាន និងរូបថតចំនួន ៥២០សន្លឹក ជូនអង្គភាពចំណុះអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា<br>- បានទទួលមន្ត្រីរាជការ សិស្ស និស្សិត និង |

| | |
|---|---|
| យល់អំពីសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា<br>- ព្រឹទ្ធសភាបានទទួលពាក្យបណ្តឹងចំនួន០២ករណី ផ្ញើពាក្យបណ្តឹងចេញទៅក្រសួង ខេត្ត ក្រុង និងស្ថាប័នពាក់ព័ន្ធចំនួន០៦ករណី ព្រមទាំងកំពុងសិក្សាចំនួន០២ករណី និងផ្ញើលិខិតរំលឹកជំរុញការដោះស្រាយពាក្យបណ្តឹងចំនួន០១ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងបានចំនួន១៥ករណី ទទួលឯកសារពាក្យបណ្តឹងពីក្រសួង ស្ថាប័ន ដែលចម្លងជូនមកព្រឹទ្ធសភាជ្រាបចំនួន១២ករណី<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះតាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញទូទាំងប្រទេសចំនួន៨៨លើក ដើម្បីជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព សិក្សាឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ | សាធារណជនចូលអានសៀវភៅចំនួន១១៦នាក់ អនុញ្ញាតឱ្យខ្ចីសៀវភៅចំនួន៣០ក្បាល និងសងវិញចំនួន៣៥ក្បាល ព្រមទាំងបានធ្វើកាតសមាជិកបណ្ណាល័យជូនសិស្ស និងនិស្សិតចំនួន០៥នាក់<br>- បានទទួលឯកសារ សៀវភៅ ព្រឹត្តិបត្រ ទស្សនាវដ្តី និងកាសែតចំនួន១៦៧ក្បាល ពីអង្គការ ស្ថានទូត ក្រសួង ស្ថាប័ន វិទ្យាស្ថានអប់រំ សប្បុរសជន និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានផលិតប្រតិទិនព្រឹទ្ធសភាប្រចាំ២០១៩ ចំនួន ២៥០០ច្បាប់<br>- បានកំពុងផលិតសៀវភៅទិនានុលេខន៍ និងប្រតិទិនផែនការខែឆ្នាំ២០១៩<br>- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ព្រឹទ្ធសភាចំនួន៤៧លើក<br>- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃសរុបចំនួន៥២លើក។ |

| | |
|---|---|
| ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការផ្សេងៗ សរុបចំនួន១៤៦លើក។ | |

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ :**

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សម្តេចប្រធានព្រឹទ្ធសភា បានអនុញ្ញាតឱ្យសមាជិកការិយាល័យនយោបាយមជ្ឈិមបក្ស លេខាមជ្ឈិមបក្ស និងជាប្រធានគណៈកម្មការចលនាមហាជនមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម អនុប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជនចិនទូទាំងប្រទេស និងឯកអគ្គរដ្ឋទូតឡាវ ចូលជួបសវនាការ សម្តែងការគួរសម និងជម្រាបលា<br>- ឯកឧត្តមប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានជួបពិភាក្សាការងារ ជាមួយទីប្រឹក្សាជាន់ខ្ពស់នៃកម្មវិធី FACT នៃវិទ្យាស្ថានសភាកម្ពុជា (PIC)<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញទៅចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ទទួលបន្ទុកកិច្ចការនយោបាយ និងកិច្ចប្រជុំគណៈកម្មាធិការពិសេសស្តីពី ការបង្កើតសភាអាស៊ី (SCCAP) នៃសភាតំបន់អាស៊ី (APA) នៅសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន និងអញ្ជើញទៅបំពេញទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍ និងព័ត៌មាន នៅព្រឹទ្ធសភានៃសាធារណរដ្ឋបារាំង និងនៅព្រឹទ្ធសភានៃប្រទេសអូស្ត្រាលី ព្រមទាំងអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការ និងចូលរួមវេទិកាទន្ទេឈានថាង លើកទី២ | - សហប្រតិបត្តិការជាមួយវិទ្យាស្ថានសភាកម្ពុជា (PIC) តាមការប្រែប្រួលថ្មី ដែលយកប៉ូលតំបន់ជាឧត្តមភាព<br>- ថ្នាក់ដឹកនាំអគ្គលេខាធិការព្រឹទ្ធសភា បានជួបពិភាក្សាការងារជាមួយឯកអគ្គរដ្ឋទូតរុស្ស៊ី និងទីប្រឹក្សាជាន់ខ្ពស់នៃកម្មវិធី FACT នៃវិទ្យាស្ថានសភាកម្ពុជា(PIC)<br>- បានរៀបចំពិធីបដិសណ្ឋារកិច្ច ដំណើរទស្សនកិច្ចផ្លូវការរបស់គណៈប្រតិភូអន្តរជាតិ ឥស្សរជននយោបាយ អគ្គទូត និងអង្គការអន្តរជាតិនានា<br>- បានរៀបចំទីកន្លែងជូនសម្តេចប្រធានព្រឹទ្ធសភាជួបសវនាការ សម្តែងការគួរសម និងពិធីផ្សេងៗជាមួយភ្ញៀវអន្តរជាតិចំនួន០៣លើក<br>- បានថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំជួបភ្ញៀវជាតិ និងអន្តរជាតិ មកបំពេញទស្សនកិច្ចនៅព្រឹទ្ធសភាចំនួន២៨លើក<br>- បានរៀបចំសម្អាត តុបតែងលម្អសាល ផ្គត់ផ្គង់សម្ភារៈប្រើប្រាស់ បម្រើសេវាភេសជ្ជៈ និងអាហារសម្រន់ ក្នុងកិច្ចប្រជុំសរុបចំនួន១២លើក មានអ្នកចូលរួមចំនួន២៩២នាក់<br>- បានថតចម្លងឯកសារចំនួន៨០ច្បាប់ អស់ក្រដាសចំនួន១,០៤៦សន្លឹក<br>- បានផ្តល់សេវារថយន្តសម្រាប់ថ្នាក់ដឹកនាំ |

| | |
|---|---|
| ឆ្នាំ២០១៨ នៅសាធារណរដ្ឋប្រជាមានិតចិន។ | សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះតាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន៨១នាក់ ស្មើនឹង៥៣លើក<br>- បានធ្វើកំណត់បង្ហាញ កំណត់ហេតុ កំណត់ទូតសំណើ និងលិខិតឆ្លើយតបទៅក្រសួង ស្ថាប័នផ្សេងៗ និងបណ្តាអង្គទូតនានាចំនួន២៦លើក<br>- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២២នាក់ ស្មើនឹង០៩ច្បាប់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកសមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញទៅបំពេញបេសកកម្មនៅក្រៅប្រទេស ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន២៧លើក<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន១០០នាក់ ស្មើនឹង០៤លើក<br>- បានរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកសមាជិកាព្រឹទ្ធសភា អញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការ ចូលរួមវេទិកា និងកិច្ចប្រជុំផ្សេងៗនៅក្រៅប្រទេសចំនួន០៤លើក<br>- បានរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការ ចូលរួមវេទិកា មហាសន្និបាត និងកិច្ចប្រជុំផ្សេងៗនៅក្រៅប្រទេសចំនួន០៥លើក<br>- បានទំនាក់ទំនងជាមួយបណ្ណាល័យនានា ដើម្បីស្នើសុំ និងទទួលសៀវភៅផ្សេងៗ<br>- បានសហការ និងទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន |

| | |
|---|---|
| | នានា ដើម្បីសម្របសម្រួលដល់កិច្ចការអន្តរជាតិ ដំណើរទស្សនកិច្ច សិក្ខាសាលា បេសកកម្ម ក្នុង និងក្រៅប្រទេស ស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ព្រមទាំងការរៀបចំពិធីផ្សេងៗ។ |

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន :**

| *វចនាសម្ព័ន្ធនយោបាយ* | *វចនាសម្ព័ន្ធរដ្ឋបាល* |
|---|---|
| | + បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៤១៥ច្បាប់<br>+ បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្តីពី សកម្មភាពការងារព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែវិច្ឆិកាឆ្នាំ២០១៨ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២៧០ច្បាប់។<br>+ ការងារគ្រប់គ្រងបុគ្គលិក:<br>- បានរៀបចំលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការសរុបចំនួន៧១ច្បាប់<br>- ប្រជុំគណៈកម្មការគោលនយោបាយស្តីពី របៀបរបបសុំច្បាប់ និងការអនុញ្ញាតច្បាប់ ឈប់សម្រាកគ្រប់ប្រភេទរបស់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានរៀបចំប្រគល់ប័ណ្ណសមាជិក ប.ស.ស និងបានផ្សព្វផ្សាយអំពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម ជូនដល់មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានធ្វើបែបបទស្នើសុំគ្រឿងឥស្សរិយយសជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានរៀបចំធ្វើបច្ចុប្បន្នភាពវចនាសម្ព័ន្ធ តួនាទី |

| | |
|---|---|
| | ភារកិច្ច និងសមត្ថកិច្ចនៃអគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា<br>- បានរៀបចំមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភាទៅតាមរចនាសម្ព័ន្ធថ្មី។<br>+ ការងារបណ្តុះបណ្តាលធនធានមនុស្ស:<br>- បានបើកវគ្គបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស ចំនួន០៥វគ្គ មានសិក្ខាកាមសរុបចំនួន៨០នាក់ សិក្ខាសាលានៅក្រៅប្រទេសចំនួន០១លើក មានសិក្ខាកាមចូលរួមចំនួន០២នាក់។<br>+ ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:<br>- បានប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ប្រជុំពិនិត្យគោលការណ៍ហិរញ្ញវត្ថុ សម្រាប់អនុវត្ត ឆ្នាំ២០១៩ និងការបែងចែកកញ្ចប់ថវិកាឆ្នាំ២០១៩ សម្រាប់រចនាសម្ព័ន្ធនយោបាយ និងរដ្ឋបាល<br>- បានរៀបចំរបាយការណ៍ចំនួនមន្ត្រីក្របខ័ណ្ឌ និង បុគ្គលិកជាប់កិច្ចសន្យា របាយការណ៍ប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់វិភាជន៍ផ្សេងៗ និង របាយការណ៍ចំណាយថវិកាធៀបអាណត្តិប្រចាំខែ ព្រមទាំងធ្វើតារាងប្រាក់ឧបត្ថម្ភរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារផ្សេងៗ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំនានាចំនួន ១២៩សំណើ បានផ្គត់ផ្គង់សម្ភារៈអនាម័យ សម្ភារៈការិយាល័យ និងកេសជ្ជៈចំនួន៥៦សំណើ សម្រាប់កិច្ចប្រជុំផ្សេងៗ និងជូនគ្រប់អង្គភាព |

ចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានរៀបចំសម្អាត តុបតែងសាលប្រជុំ ផ្ដល់សេវាភេសជ្ជៈ និងអាហារសម្រន់ក្នុងពិធីផ្សេងៗចំនួន ២៧លើក មានអ្នកចូលរួមចំនួន៥៨៥នាក់
- បានផ្ដល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន១៤២លើក
- បានថតចម្លងឯកសារចំនួន៧,២៦៧ច្បាប់ និងចងក្រងសៀវភៅចំនួន៥៤ក្បាល អស់ក្រដាសចំនួន៣៤,៧៩២សន្លឹក និងជួសជុល សម្អាតម៉ាស៊ីនថតចម្លង និងម៉ាស៊ីនព្រីនធ័រចំនួន១៧លើក
- បានផ្ដល់សេវារថយន្តជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងរាជធានីភ្នំពេញចំនួន ១៥នាក់ ស្មើនឹង០៥លើក។

+ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្តរឹង និងទន់ :

- កសាងអគារថ្មី០១ខ្នង សម្រាប់ជាកន្លែងធ្វើការរបស់វិទ្យាស្ថានសភាកម្ពុជា(PIC)
- រៀបចំក្រាលព្រំនៅតាមអគារD,E,F
- រៀបចំជួសជុលកែលម្អបន្ទប់សិក្សា របស់នាយកដ្ឋានព័ត៌មានវិទ្យា និងបន្ទប់ទីប្រឹក្សាចិន
- បានជួសជុលកែលម្អ និងពង្រីកអគារបណ្ណាល័យ ទីកន្លែងធ្វើការរបស់ការិយាល័យជួសជុល
- សាងសង់រួចរាល់រោងចំណតរថយន្តនៅខាងមុខអគារបណ្ណាល័យ និងបញ្ចប់ការកែលម្អបញ្ជរបិទរូបថតនៅខាងមុខព្រឹទ្ធសភា
- ជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ

| | |
|---|---|
| | បណ្តាញទឹក និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម បិទលេខកូដសម្ភារៈសារពើភ័ណ្ឌ និងប្រគល់សម្ភារៈជូនគណៈកម្មការទី១០ ព្រមទាំងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាសរុបចំនួន១៧៨គ្រឿង<br>- បានរៀបចំកែលម្អបរិស្ថានក្នុងបរិវេណព្រឹទ្ធសភាឱ្យមានសោភ័ណភាពល្អ<br>- បានតាំងពិព័រណ៍រូបភាព និងចងបដា ពាក្យស្លោកធ្វើហ្វុងអក្សរចំនួន០៦លើក<br>- សហការជាមួយក្រុមហ៊ុនកំចាត់សត្វកណ្តៀរ និងសហការប្រចាំការម៉ាស៊ីនភ្លើង នៅតាមសាលប្រជុំព្រមទាំងបានត្រួតពិនិត្យមើលការប្រើប្រាស់ទឹកភ្លើង ក្រោយម៉ោងរដ្ឋបាល និងថ្ងៃឈប់សម្រាកសរុបចំនួន៩២លើក<br>- ចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Connect Wifi និងជួសជុលម៉ាស៊ីនកុំព្យូទ័រដាក់កម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធី Unicode និង Set up កម្មវិធីសរុបចំនួន៣៣គ្រឿង។ បានUpload សេចក្តីជូនដំណឹងព្រឹត្តិបត្រព័ត៌មានសុខភាព ទស្សនាវដ្តី និងរូបភាពសកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភាលើគេហទំព័រព្រឹទ្ធសភាសរុបចំនួន៦៧ចំណងជើង។<br>+ ការងារផ្សេងៗ<br>- បានផលិតព័ត៌មានទាន់ហេតុការណ៍ និងផលិតខ្សែវីដេអូ សម្រាប់បង្ហោះលើ Alert News ចំនួន១២០ប្រធានបទ<br>- ថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំក្នុងកម្មវិធីផ្សេងៗចំនួន២៦លើក |

| | |
|---|---|
| | - បានបញ្ចូលសៀវភៅកាសាអង់គ្លេសក្នុងកម្មវិធី KOHA និងអ៊ិតក្របសៀវភៅ ព្រមទាំងជួសជុលឯកសារ និងសៀវភៅចាស់ៗសរុបចំនួន១៨៧ក្បាល<br>- បញ្ចូលទិន្នន័យសៀវភៅព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ច្បាប់ កាសែត ទស្សនាវដ្ដី ព្រឹត្តិបត្រ រាជកិច្ច និងបញ្ចូលសៀវភៅតាមE-Library តាមបណ្ដាញ Facebookសរុបចំនួន៦,៣៨២ក្បាល។ |

II.**ទិសដៅការងារខែធ្នូ ឆ្នាំ២០១៨**

**១.មុខងារនីតិកម្ម**:

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៤។

**២.មុខងារតាមដានការអនុវត្តច្បាប់និងគោលនយោបាយនានា** :

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួង ស្ថាប័ននានា និងការចុះបេសកកម្មទៅតាមបណ្ដាខេត្តនានា។

**៣.មុខងារតំណាង** :

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភាប្រជុំជាមួយគណៈកម្មការរៀបចំបុណ្យជាតិនានា (ទិវាឈ្នះ-ឈ្នះ និងទិវា២ធ្នូ)

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមក្នុងពិធីផ្លូវការនានា នៅតាមបណ្ដាខេត្ត ក្រុង និងរាជធានីភ្នំពេញ

-ត្រៀមរៀបចំវេទិកាតាមភូមិភាគ សិក្ខាសាលា និងពិធីសំណេះសំណាលផ្លូវការផ្សេងៗ

-ត្រៀមទទួលមន្ត្រីរាជការ យុវជន សិស្ស និស្សិត និងសាធារណជនមកទស្សនកិច្ចនៅព្រឹទ្ធសភា។

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ** :

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូបរទេស និងអគ្គទូតនានា

-ត្រៀមទទួលគណៈប្រតិភូអគ្គលេខាធិការព្រឹទ្ធសភាឥណ្ឌូណេស៊ី គណៈប្រតិភូសភាប្រឹក្សានយោបាយខេត្តចិន និងគណៈប្រតិភូប្រធានព្រឹទ្ធសភារុស្ស៊ី

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាទៅបំពេញបេសកកម្មក្រៅប្រទេស

-ការចូលរួមវេទិកា APPFនាខែមករា ឆ្នាំ២០១៩ និងកម្មវិធីតំបន់វិទ្យាស្ថានសភាកម្ពុជា(PIC) នៅខេត្តសៀមរាប

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា។

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

-បន្តតាមដានជំនួយរបស់សាធារណរដ្ឋប្រជាមានិតចិន

-រៀបចំជួសជុលកែលម្អអគារសាលប្រជុំបណ្ណាល័យឡើងវិញ

-បន្តកសាងអគាររបស់វិទ្យាស្ថានសភាកម្ពុជា(PIC)

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ ការសន្សំសំចៃទឹកភ្លើង ការគ្រប់គ្រងការប្រើប្រាស់ Internet

-ការចាប់ផ្តើមរៀបចំប្រព័ន្ធ Website/Webpageក្នុងកម្រិតអគ្គនាយកដ្ឋាន គណៈកម្មការ និងក្រុមនានា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល គ្រប់គ្រងបុគ្គលិក តាមប្រព័ន្ធព័ត៌មានវិទ្យា កសាង Program និង Software ដើម្បីអនុវត្តតាមអង្គភាព និងការបណ្តុះបណ្តាលក្នុងនោះចូលអនុវត្តកម្មវិធី Eបណ្ណាល័យ និង E បណ្ណសារ

-អនុវត្តគម្រោងបច្ចុប្បន្នភាពរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាតាមតម្រូវការថ្មី និងត្រៀមឯកសារឆ្លងគណៈកម្មាធិការអចិន្ត្រៃយ៍

-ពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធតួនាទី ភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តប្រជុំគណៈកម្មការគោលការណ៍ និងគោលនយោបាយនានារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តិ បម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ជំរុញការស្នើសុំអាហារូបករណ៍ និងដាក់ពាក្យប្រលងអាហារូបករណ៍ពីប្រទេសផ្សេងៗទៀត ឆ្នាំ២០១៩

-ត្រៀមរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិរបស់ក្រុមសមាជិកព្រឹទ្ធសភា នីតិកាលទី៤ ប្រចាំភូមិភាគទាំង៨

-ត្រៀមធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្ររបស់អគ្គលេខាធិការដ្ឋាន និងអគ្គនាយកដ្ឋាន

-ត្រៀមរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិទ្យាស្ថានកម្ពុជា(PIC) អភិវឌ្ឍធនធានមនុស្ស ព័ត៌មាន និងទំនាក់ទំនងសាធារណៈ ការស្រាវជ្រាវ និងសហប្រតិបត្តិការអន្តរជាតិ

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងតម្រូវការជាក់ស្តែង

-សិក្សាអំពីការប្រារព្ធខួបអនុស្សាវរីយ៍គម្រប់២០ឆ្នាំនៃការបង្កើតព្រឹទ្ធសភា (ថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩ ដល់ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩)

-ត្រៀមចូលរួមរៀបចំទិវាសិទ្ធិមនុស្សអន្តរជាតិ

-ត្រៀមបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងទិសដៅការងារឆ្នាំ២០១៩

-ត្រៀមរៀបចំរបាយការណ៍ទូទាត់ថវិកាឆ្នាំ២០១៨ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍

- ត្រៀមបោះពុម្ពដំណាច់ឆ្នាំៈ ទិនានុលេខន៍

-ត្រៀមរៀបចំផែនការថវិកាតាមកម្មវិធីរួម និងតាមអង្គភាពថវិកា

-ត្រៀមកែសម្រួលគោលការណ៍ហិរញ្ញវត្ថុថ្មីសម្រាប់អនុវត្តចាប់ពីឆ្នាំ២០១៩ និងការបែងចែកកញ្ចប់ថវិកាឆ្នាំ២០១៩ សម្រាប់រចនាសម្ព័ន្ធនយោបាយ និងរដ្ឋបាល។

III.**សេចក្តីសន្និដ្ឋាន**

ខែវិច្ឆិកានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរៀបចំ និងចាត់ចែងការងារ ជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាលើសេវាទ្រទ្រង់មុខងារនីតិកម្ម ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក បានយ៉ាងល្អប្រសើរ។ លើមុខងារតំណាង បានចុះតាមមូលដ្ឋាន ដើម្បីឈ្វេងយល់អំពីសុខទុក្ខ ដោះស្រាយបញ្ហាប្រឈម និងសំណូមពរនានា របស់ប្រជាពលរដ្ឋ។ ចំពោះការអភិវឌ្ឍស្ថាប័ន បានពង្រឹងសមត្ថភាពមន្ត្រីរាជការទាំងអស់ឱ្យក្លាយជាអ្នកពូកែពហុវិស័យ ទាំងចំណេះដឹង ជំនាញ ឯកទេស និងសមត្ថភាពភាសាបរទេស។ កិច្ចសហប្រតិបត្តិការអន្តរជាតិ ត្រូវបានពង្រឹងពង្រីក និងលើកកម្ពស់តាមរយៈការចូលរួមប្រជុំ មហាសន្និបាត និងទស្សនកិច្ចសិក្សា ព្រមទាំងការស្វែងរកជំនួយពីប្រភពខាងក្រៅបន្ថែមទៀត ។

ការចូលរួមថែទាំឱ្យបានល្អនូវហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដូចជាប្រព័ន្ធទឹក អគ្គិសនី ផ្ទល់លូបង្ហូរទឹក បរិស្ថាន សួនច្បារ និងប្រព័ន្ធចរាចរ ។ល។ គឺជាកាតព្វកិច្ចរួម។

ការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធរដ្ឋបាល គឺជាជំហានមួយដ៏សំខាន់នៅក្នុងដំណើរទៅមុខរបស់ព្រឹទ្ធសភាក្នុងឆ្នាំខាងមុខ។

ការធ្វើដំណើរមកដល់ចុងឆ្នាំទាមទារឱ្យធ្វើការបូកសរុប វាយតម្លៃ ពិចារណា គិតគូរ រៀបចំលើកផែនការ និងត្រៀមខ្លួនសម្រាប់ឆ្នាំ២០១៩ ខាងមុខ ដែលពិតជាត្រូវការនូវសកម្មភាពថ្មី និងសន្ទុះការងារថ្មីបន្ថែមទៀត។៨

ថ្ងៃអង្គារ ៥កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៨

**អគ្គលេខាធិការ**

អ៊ុំ_សារឹទ្ធ